# I . ទីស្តីការគណៈរដ្ឋមន្ត្រី

## ១- សេចក្តីសំរេច

*រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៩៤*

### សេចក្តីសំរេចលេខ ១១៥ សសរ.

ស្តីពីការបង្កើតគណៈកម្មការសាងសង់ស្ថានីយវារីអគ្គិសនីអូរជុំ I

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
-បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ័ន្ត ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

**សំរេច**

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការសាងសង់ស្ថានីយវារីអគ្គិសនីអូរជុំ I សំរាប់ដឹកនាំ ជំរុញសកម្មភាពការងារ ជាយន្តការជំនួយរបស់រាជរដ្ឋាភិបាល ក្នុងការតាមដានការអនុវត្តន៍កម្មវិធី សាងសង់ស្ថានីយវារីអគ្គិ សនី អូរជុំ I ។

សមាសភាពរបស់គណៈកម្មការ មានដូចខាងក្រោមនេះ ៖

១- ឯកឧត្តម អ៊ិត ប្រាំង អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ប្រធាន

២- ឯកឧត្តម ជីន គីមស្រេង អនុរដ្ឋលេខាធិការក្រសួងសាធារណៈការ អនុប្រធាន

៣- ឯកឧត្តម ឈា សុខ អនុរដ្ឋលេខាធិការក្រសួងកសិកម្ម សមាជិក

៤- ឯកឧត្តម ជា រេម៉ងឈាង អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

៥- ឯកឧត្តម អ៊ូ ឱហាត អនុរដ្ឋលេខាធិការក្រសួងផែនការ សមាជិក

៦- ឯកឧត្តម ប៊ុន ហួចមុនី អភិបាលរងខេត្តរតនៈគីរី សមាជិក

៧- លោក ញឹក ទ្រឹង ប្រធាននាយកដ្ឋានថាមពល នៃ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល លេខាអចិន្ត្រៃយ៍

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ចដូចតទៅ ៖

- កំណត់ស្ថាប័នប្រត្តិបត្តិការងារសាងសង់
- តាមដានអនុវត្ត កម្មវិធី បង្កលក្ខណៈងាយស្រួល និង សំរប សំរួល ដល់កិច្ចដំណើរកម្មវិធី
- រាយការណ៍ជូនរាជរដ្ឋាភិបាល នូវរាល់បញ្ហា លទ្ធផលនៃការអនុវត្តន៍ ។

ប្រការ ៣ : គណៈកម្មការមានសិទ្ធិប្រើប្រាស់ត្រា របស់ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល លើរាល់លិខិតបទដ្ឋាននានាដែលទាក់ទិន ក្នុងការងារសាងសង់ស្ថានីយវារីអគ្គិសនីអូរជុំ I ។

ប្រការ ៨ : រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល រដ្ឋមន្ត្រីក្រសួងកសិ-កម្ម រដ្ឋមន្ត្រី ក្រសួងសាធារណៈការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ និង ឯកឧត្តម លោក ដែលមានឈ្មោះក្នុង ប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និង ត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និង ត្រា
ហ៊ុន សែន

* * *

*រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៩៤*

## សេចក្តីសំរេចលេខ ១១៦ សសរ.

## ស្តីពីការបង្កើតគណៈកម្មការស្រាវជ្រាវបំណុល

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមស្មារតីសំរេច របស់សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ១៩៩៤